ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ធនាគារជាតិ នៃ កម្ពុជា

លេខ.......................................................

# មតិសំណេះសំណាល
# លោកជំទាវបណ្ឌិត ជា សិរី អគ្គទេសាភិបាល ធនាគារជាតិនៃកម្ពុជា
# ថ្លែងក្នុងពិធីអបអរសាទរដល់សិស្សថ្នាក់ទី១២ ដែលប្រឡងជាប់ជាស្ថាពរ
# សញ្ញាបត្រមធ្យមសិក្សាទុតិយភូមិឆ្នាំសិក្សា ២០២៣-២០២៤
# នៅស្នាក់ការគណបក្សស្រុកសន្ទុក ខេត្តកំពង់ធំ

ថ្ងៃអង្គារ ១២កើត ខែកត្តិក ឆ្នាំរោង ឆស័ក ព.ស.២៥៦៨
ត្រូវនឹងថ្ងៃទី១២ ខែវិច្ឆិកា ឆ្នាំ២០២៤

ជាបឋម សូមគោរព

- គណៈអធិបតី នាយក-នាយករង លោកគ្រូ-អ្នកគ្រូ លោក-លោកស្រី
- សួស្តី ក្មួយៗ សិស្សានុសិស្សទាំងអស់ជាទីរាប់អាន!

ថ្ងៃនេះ ខ្ញុំមានក្តីសោមនស្សរីករាយជាអនេក ដោយបានចូលរួមក្នុងពិធីអបអរសាទរដល់សិស្សានុសិស្ស ដែលបានប្រឡងជាប់ជាស្ថាពរសញ្ញាបត្រមធ្យមសិក្សាទុតិយភូមិសិក្សា ២០២៣-២០២៤ សរុបចំនួន ៥២៧រូប ក្នុងនោះមានស្រីចំនួន ៣២៣រូប នៅក្នុងវិទ្យាល័យទាំង៣ របស់ស្រុកសន្ទុកយើងនេះ រួមមាន៖ វិទ្យាល័យហ៊ុន សែន ភ្នំសន្ទុក វិទ្យាល័យតាំងក្រសាំង និងវិទ្យាល័យកំពង់ថ្ម។ ខ្ញុំសូមកោតសរសើរ និងវាយតម្លៃខ្ពស់ចំពោះជោគជ័យរបស់ក្មួយៗ ដែលពិតជាបានបង្ហាញពីស្មារតីតស៊ូ អត់ធ្មត់ ខិតខំប្រឹងប្រែង និងយកចិត្តទុកដាក់រៀនសូត្រ រហូតសម្រេចបានលទ្ធផលជាវិជ្ជមាននេះ។ ការខិតខំព្យាយាមរៀនសូត្រកន្លងមកនេះ ពិតជាបាននាំមកនូវកិត្តិយស និងសេចក្តីថ្លៃថ្នូរជូនក្រុមគ្រួសារក្មួយៗ និងសង្គមជាតិយើង ជាពិសេស ស្រុកសន្ទុកយើងទាំងមូល។

ខ្ញុំសូមចូលរួមអបអរសាទរជាមួយមាតាបិតា អាណាព្យាបាល និងលោកគ្រូ-អ្នកគ្រូរបស់ក្មួយៗ ចំពោះលទ្ធផលនៃការសិក្សាដ៏ល្អប្រសើរដែលលោក ឡុង គីសឹង អភិបាលស្រុកសន្ទុក បានធ្វើរបាយការណ៍មុននេះ។ នៅទូទាំងខេត្តកំពង់ធំយើង មានបេក្ខជនប្រឡងសរុបចំនួន ៥.៦៥៨រូប ស្រី ៣.២៧៣រូប ក្នុងនោះ ស្រុកសន្ទុកយើងមានបេក្ខជនប្រឡងសរុបចំនួន ៦១៧រូប ស្រី ៣៦១រូប ជាលទ្ធផលនៃការខិតខំរបស់ក្មួយៗ អ្នកដែលបានប្រឡងជាប់ជាស្ថាពរថ្នាក់ខេត្តមានចំនួន ៤.៧៣២រូប ស្រី ២.៨៥៤រូប ដែលស្រុកសន្ទុកយើងមានបេក្ខជនប្រឡងជាប់ជាស្ថាពរចំនួន ៥២៧រូប ស្រី ៣២៣រូប បើយើងប្រៀបធៀបទៅនឹងឆ្នាំកន្លងទៅ គឺកើនឡើង ១៦,៨៥% (ឆ្នាំសិក្សា ២០២២-២០២៣)។ ទន្ទឹមនេះ ជាមោទនភាពផងដែរ ដែលយើងមានក្មួយៗចំនួន ៣រូប ស្រី ២រូប មកពីវិទ្យាល័យកំពង់ថ្ម ទទួលបាននិទ្ទេស A សូមអបអរសាទរ។ លទ្ធផលរបស់ក្មួយៗទាំងអស់គ្នាពុំមែនជាជោគវាសនាទេ ប៉ុន្តែគឺជាការវាស់ស្ទង់សមត្ថភាពពិតៗរបស់ក្មួយៗ។


ប្រអប់សំបុត្រលេខ ២៥, ឡូត៍លេខ ៨៨ ផ្លូវលេខ ១០២ កែងនឹងផ្លូវលេខ ១៩ សង្កាត់វត្តភ្នំ ខណ្ឌដូនពេញ រាជធានីភ្នំពេញ , ទូរស័ព្ទ : (៨៥៥-២៣) ៧២២ ៥៦៣, ទូរស័ព្ទ / ទូរសារ : (៨៥៥-២៣) ៤២៦ ១១៧

**ឯកឧត្តម លោកជំទាវ លោក-លោកស្រី លោកគ្រូ-អ្នកគ្រូ និងក្មួយៗទាំងអស់ ជាទីមេត្រី!**

ក្រោមដំបូលសន្តិភាពដែលជាមរតកដឹកនាំរបស់ **សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន** ប្រធានព្រឹទ្ធសភានៃព្រះរាជាណាចក្រកម្ពុជា រាជរដ្ឋាភិបាលនីតិកាលថ្មីដែលដឹកនាំដោយ **សម្តេចមហាបវរធិបតី ហ៊ុន ម៉ាណែត** បាននិងកំពុងដឹកនាំប្រទេសជាតិយើងប្រកបដោយភាពស្វាហាប់ និងសមាហរណកម្មជាតិនិងអន្តរជាតិ ដើម្បីបន្តបេសកកម្មដ៏ពិសិដ្ឋរបស់រាជរដ្ឋាភិបាលនីតិកាលចាស់ក្នុងការរក្សាឱ្យបានសុខសន្តិភាពដែលជាខឿនជានាសេចក្តីសុខរបស់ប្រជាពលរដ្ឋ ជំរុញដល់កំណើនសេដ្ឋកិច្ច និងការអភិវឌ្ឍបានសមិទ្ធផលថ្មីៗបន្តទៀត ដើម្បីឆ្លើយតបសេចក្តីត្រូវការពិតប្រាកដរបស់ប្រជាពលរដ្ឋ។

រាជរដ្ឋាភិបាលបានដាក់ចេញ «យុទ្ធសាស្ត្របញ្ចកោណ-ដំណាក់កាលទី ១» ដោយមានបញ្ចកោណយុទ្ធសាស្ត្រទី ១ ផ្តោតជាចម្បងលើការអភិវឌ្ឍមូលធនមនុស្ស ដែលជាលក្ខខណ្ឌចាំបាច់មិនអាចខ្វះបានសម្រាប់ជំរុញពិពិធកម្ម កំណើនសេដ្ឋកិច្ច និងការអភិវឌ្ឍសង្គម-សេដ្ឋកិច្ចជាតិ ប្រកបដោយបរិយាប័ន្ន និងភាពធន់។ ក្នុងន័យនេះ រាជរដ្ឋាភិបាលផ្តោតលើអាទិភាពចំនួន ៥ សម្រាប់កសាងមូលធនមនុស្សរឹងមាំ រួមមាន៖ ១/- ការពង្រឹងគុណភាពវិស័យអប់រំ កីឡា វិទ្យាសាស្ត្រ និងបច្ចេកវិទ្យា ២/- ការបណ្តុះបណ្តាលជំនាញបច្ចេកទេស ៣/- ការលើកកម្ពស់សុខភាព និងសុខុមាលភាពប្រជាជន ៤/- ការពង្រឹងប្រព័ន្ធគាំពារសង្គម និងប្រព័ន្ធស្បៀង និង៥/- ការពង្រឹងភាពជាពលរដ្ឋក្នុងសង្គម ដែលមានអារ្យធម៌ខ្ពស់ប្រកបដោយសីលធម៌ សមធម៌ និងបរិយាប័ន្ន។ ជាគោលដៅនៃការអប់រំ គឺមិនមែនតែជំនាញរឹងទេ គឺទាំងជំនាញទន់ផង មានន័យថា មិនត្រឹមតែចំណេះដឹងបទពិសោធន៍ការងារប៉ុណ្ណោះទេ តែក៏ត្រូវអប់រំឥរិយាបថផង។ ផលិតមនុស្សម្នាក់មិនមែនឱ្យតែពូកែធ្វើការពូកែប្រកួតប្រជែង ដោយមិនមានក្រឹត្យក្រមសីលធម៌បាននោះទេ។ ចេញមកត្រូវតែចេះប្រកួតប្រជែងដោយវិជ្ជមាន ចេះជួយយកអាសារគ្នា ចេះមានក្រមសីលធម៌ល្អ ដែលជាពលរដ្ឋល្អ ដើម្បីយើងរួមគ្នាកសាងប្រទេសជាតិ។

**ឯកឧត្តម លោកជំទាវ លោក-លោកស្រី លោកគ្រូ-អ្នកគ្រូ និងក្មួយៗទាំងអស់ ជាទីមេត្រី!**

ប្រទេសកម្ពុជាយើង បានឈានឡើងពីប្រទេសដែលមានចំណូលទាប ទៅជាប្រទេសដែលមានចំណូលមធ្យមកម្រិតទាប ចាប់តាំងពីឆ្នាំ២០១៥ មក។ ភាពក្រីក្រត្រូវបានកាត់បន្ថយយ៉ាងឆាប់រហ័សឆ្លុះបញ្ចាំងតាមរយៈកំណើនចំណូលរបស់ប្រជាជនម្នាក់ៗពី ៣៣៨ដុល្លារអាមេរិក នៅឆ្នាំ២០០២ រហូតដល់ ១.៨៧៥ដុល្លារអាមេរិក នៅឆ្នាំ២០២៣ និងរំពឹងថាកើនដល់ជាង ២ពាន់ដុល្លារ ក្នុងឆ្នាំ២០២៤ នេះ។ ចំណែកឯ អាយុសង្ឃឹមរស់របស់ប្រជាជនកម្ពុជា (Life Expectancy) បានកើនពី ៥៥ឆ្នាំ នៅឆ្នាំ១៩៩៥ ដល់ ៧៥ឆ្នាំ នៅឆ្នាំ២០២៤។

សមិទ្ធផលទាំងអស់នេះគឺបានមកពីកត្តាសុខសន្តិភាព និងស្ថិរភាពនយោបាយរបស់ប្រទេសជាតិទាំងមូលដែលជាមូលដ្ឋានគ្រឹះដ៏រឹងមាំក្នុងការពង្រឹងជំនឿទុកចិត្តរបស់វិនិយោគិន ដៃគូពាណិជ្ជកម្ម ដៃគូអភិវឌ្ឍន៍ និងភាគីពាក់ព័ន្ធនានា ឱ្យចូលរួមយ៉ាងសកម្មក្នុងការអភិវឌ្ឍសេដ្ឋកិច្ច-សង្គម ជាពិសេស បានគាំទ្រដល់ការអនុវត្តកម្មវិធីកែទម្រង់ស៊ីជម្រៅរបស់រាជរដ្ឋាភិបាល ឱ្យសម្រេចបានជាបន្តបន្ទាប់ប្រកបដោយប្រសិទ្ធភាពនិងផ្លែផ្កាខ្ពស់។ ជាមួយគ្នានេះដែរ ក្រោមគោលនយោបាយសេដ្ឋកិច្ចបើកចំហ និងបង្កើនសមាហរណកម្មទៅក្នុងតំបន់និងពិភពលោក គួបផ្សំនឹងភាពប្រសើរឡើងនៃស្ថានភាពសេដ្ឋកិច្ចពិភពលោក បានរួមចំណែកយ៉ាងសំខាន់ក្នុងការគាំទ្រសសរស្តម្ភសេដ្ឋកិច្ចកម្ពុជាគឺ ការនាំចេញ វិស័យទេសចរណ៍ និងសំណង់។

នៅពេលប្រទេសជាតិកាន់តែរីកចម្រើន តម្រូវការទីផ្សារការងារកាន់តែទូលំទូលាយ ជាពិសេស ជំនាញវិជ្ជាជីវៈផ្សេងៗ ដែលអាចឆ្លើយតបទៅនឹងបរិការណ៍សេដ្ឋកិច្ចបច្ចុប្បន្ន ដូចជា ជំនាញបច្ចេកទេស ភាសាអង់គ្លេស និងកុំព្យូទ័រ ជាដើម។

ដើម្បីឆ្លើយតបនឹងបញ្ហាជំនាញ តម្រូវការទីផ្សារការងារនាពេលបច្ចុប្បន្ន និងអនាគត កាលពីថ្ងៃទី១៤ ខែវិច្ឆិកា ឆ្នាំ២០២៣ សម្តេចធិបតី **ហ៊ុន ម៉ាណែត** បានប្រកាសដាក់ឱ្យអនុវត្តជាផ្លូវការ "កម្មវិធីបណ្តុះបណ្តាលជំនាញវិជ្ជាជីវៈ និងបច្ចេកទេសសម្រាប់យុវជនមកពីគ្រួសារក្រីក្រ និងគ្រួសារងាយរងហានិភ័យ" ដើម្បីបង្កើនឱកាសទទួលបានការបណ្តុះបណ្តាលជំនាញដល់យុវជនមកពីគ្រួសារក្រីក្រ និងគ្រួសារងាយរងហានិភ័យ ដែលជាយុទ្ធសាស្ត្រគន្លឹះរបស់រាជរដ្ឋាភិបាលក្នុងការកាត់បន្ថយភាពក្រីក្រជូនប្រជាពលរដ្ឋ។

## ខ្លឹមសារជំនួយស្មារតីបន្ថែម

១/- តាមរយៈសិក្ខាសាលាស្តីពី **ការរៀបចំផែនការអាជីព និងការជ្រើសរើសជំនាញសិក្សា** កាលពីថ្ងៃទី៧ ខែកញ្ញា ឆ្នាំ២០២៤ កន្លងទៅ ខ្ញុំសង្ឃឹមថា ក្មួយៗ បានទទួលជាគតិច្រើនជាទុនក្នុងការពិចារណាសម្រេចចិត្តបន្តការសិក្សាលើមុខជំនាញណាមួយ ដែលខ្លួនឯងចូលចិត្ត និងមានទេពកោសល្យ។ ជាសាររំលឹកជាថ្មីម្តងទៀត សូមក្មួយៗកុំសម្រេចចិត្តជ្រើសរើសជំនាញ ឬការរៀនសូត្រនៅមហាវិទ្យាល័យ តាមសង្សារ ឬមិត្តភក្តិ។ ខ្ញុំជឿថា ធ្លាប់មានករណីនេះកើតឡើង ឧទាហរណ៍ ដឹងថាសង្សារសម្រេចចិត្តទៅរៀនពេទ្យ ដូច្នេះដើម្បីបានជួបមុខគេរាល់ថ្ងៃ ក៏សម្រេចចិត្តទៅរៀនពេទ្យដែរ ទាំងដែលខ្លួនឯងមិនដែលចូលចិត្តពេទ្យផងនោះ។

២/- ធនាគារជាតិនៃកម្ពុជា ក៏បាននិងកំពុងបន្តលើកកម្ពស់ការអប់រំដល់ក្មួយៗទាំងអស់ តាមរយៈការឧបត្ថម្ភវគ្គបំប៉នបន្ថែមជារៀងរាល់ឆ្នាំសម្រាប់សិស្សប្រឡងសញ្ញាបត្រមធ្យមសិក្សាទុតិយភូមិ (ថ្នាក់ទី១២) ។ ទន្ទឹមនេះ ធនាគារជាតិនៃកម្ពុជាក៏បានឧបត្ថម្ភនិងបំពាក់កុំព្យូទ័រជាច្រើនគ្រឿងនៅក្នុងបន្ទប់សិក្សាកុំព្យូទ័រ ព្រមទាំងផ្តល់ជូននូវការបង្រៀនកុំព្យូទ័រដល់ក្មួយៗ ដែលគ្រូបង្រៀនសុទ្ធសឹងជាមន្ត្រីផ្នែកព័ត៌មានវិទ្យា ដែលមានបទពិសោធន៍បម្រើការងារយូរឆ្នាំមកហើយ។ លើសពីនេះ ធនាគារជាតិនៃកម្ពុជាក៏កំពុងសស្រាក់សស្រាំក្នុងការជ្រើសរើសគ្រូបង្រៀនភាសាអង់គ្លេស ដែលជាមន្ត្រីរបស់ធនាគារជាតិនៃកម្ពុជាផងដែរ ដែលសុទ្ធសឹងមានសញ្ញាបត្របរិញ្ញាបត្រផ្នែកបង្រៀនភាសាអង់គ្លេសតែម្តង ដើម្បីផ្តល់នូវការបំពាក់បំប៉នភាសាអង់គ្លេសបន្ថែមដល់ក្មួយៗ ជាទុនសម្រាប់ត្រៀមចូលមហាវិទ្យាល័យ ឬបន្តសិក្សាជំនាញបច្ចេកទេសផ្សេងៗ។

៣/- បច្ចេកវិទ្យាមានភាពរីកចម្រើនលឿននិងខ្ពស់ ហើយក្មួយៗមានស្មាតហ្វូនសឹងគ្រប់គ្នា មានបណ្តាញសង្គមប្រើប្រាស់គ្រប់គ្នាដូចជា Facebook ជាដើម ប៉ុន្តែ វាក៏ជាអាវុធមុខពីរដែរបើសិនយើងប្រើប្រាស់វាក្នុងផ្លូវខុស។ សូមក្មួយៗគិតពិចារណាផង មុននឹង Like ឬ Share ឬ comment ថាតើព័ត៌មានទាំងនោះពិតឬក្លែងក្លាយ ជាព័ត៌មានបំពុលសង្គម ឬយ៉ាងណា។ វាជារឿងគ្រោះថ្នាក់មួយដែរ ក្នុងករណីដែលមិនទាន់បានចូលអានខ្លឹមសារព័ត៌មានផង ប៉ុន្តែ Like និង share មុនបាត់ទៅហើយ។

៤/- ផ្លូវដើររបស់ក្មួយៗនៅវែងឆ្ងាយណាស់ បើគិតចាប់ពីចំណុចត្រង់នេះ រហូតក្មួយៗទទួលបានការងារធ្វើ និងមានសេរីភាពនិងស្ថិរភាពហិរញ្ញវត្ថុបានដោយខ្លួនឯង សូមក្មួយៗបន្តព្យាយាមសិក្សារៀនសូត្រ ជៀសឱ្យឆ្ងាយពីក្រុមក្មេងទំនើង និងគ្រឿងញៀន និងចូលរួមគោរពច្បាប់

ចរាចរណ៍ទាំងអស់គ្នា ដើម្បីសុវត្ថិភាពផ្ទាល់ខ្លួន និងសហគមន៍យើង ព្រមទាំងចូលរួមថែរក្សាអនាម័យទីធ្លាសាលា ដើម្បីទទួលបានបរិស្ថានសិក្សាល្អ។

៥/- បើក្មួយៗបានសម្រេចជ្រើសរើសជំនាញដែលខ្លួនស្រលាញ់រួចហើយ ត្រូវមានស្មារតីប្តេជ្ញាចិត្តប្រឹងឱ្យអស់លទ្ធភាព។ បើចេះអីមួយ ត្រូវចេះឱ្យច្បាស់និងប្រាកដ ទើបអាចរកការងារបានល្អ។ សម្តេចធិបតីក៏ធ្លាប់មានប្រសាសន៍ថា រៀនឱ្យចប់ រៀនឱ្យចេះ និងឱ្យមានការងារធ្វើ។

៦/- ក្មួយៗ រៀបចប់ប្រឡងជាប់បាក់ឌុប ដែលទទួលបានការបណ្តុះបណ្តាលមូលដ្ឋាន គឺជាធនធានមនុស្សរបស់ប្រទេសជាតិ (Human resource)។ បន្តការសិក្សានៅមហាវិទ្យាល័យ និងទទួលបានការបណ្តុះបណ្តាលជំនាញពិតប្រាកដ គឺក្មួយៗទាំងគ្នាត្រូវបានហៅថា ជាមូលធនមនុស្ស (Human capital) សម្រាប់ប្រទេសជាតិ។ ឧទាហរណ៍ ប្រទេសសឹង្ហបុរី អត់មានធនធានធម្មជាតិដូចប្រទេសយើងទេ ប៉ុន្តែ ប្រទេសនេះ សម្បូរទៅដោយ មូលធនមនុស្ស (Human Capital) ធ្វើឱ្យប្រទេសគេមានការរីកចម្រើនយ៉ាងខ្លាំងក្នុងតំបន់អាស៊ីយើងនេះ។

៧/- ត្រូវមានគោលការណ៍ក្នុងជីវិតឱ្យបានប្រាកដនិងច្បាស់លាស់។ អភិក្រមរបស់សម្តេចធិបតី គឺរៀនឱ្យចេះ រៀនឱ្យចប់ និងឱ្យមានការងារធ្វើ។ តាមខ្ញុំដឹង បច្ចុប្បន្ន គ្រឹះស្ថានឧត្តមសិក្សាសរុបមានចំនួន ១២៨ (ទាំងរដ្ឋ និងឯកជន) កំពុងបណ្តុះបណ្តាលលើមុខជំនាញជាង ៨០មុខ។ ដូច្នេះ ក្មួយៗមានជម្រើសច្រើន ក្នុងការសម្រេចចិត្ត ប៉ុន្តែត្រូវចងចាំថា ជម្រើសទាំងនោះ ជាការឆ្លើយតបទៅនឹងចំណូលចិត្តផ្ទាល់ខ្លួន និងទេពកោសល្យរបស់ខ្លួនដែរ (មិនមែនជាការសម្រេចចិត្តរបស់សង្សារ ឬមិត្តភក្តិនោះទេ)។ ប៉ុន្តែ ក្មួយៗអាចស្វែងរកអ្នកប្រឹក្សាយោបល់ដែលទុកចិត្តបាន ដូចជា លោកគ្រូ-អ្នកគ្រូ ឬតាមរយៈការចូលរួមវេទិកាសាធារណៈស្តីពីឱកាសការងារផ្សេងៗឱ្យបានញឹកញាប់ ក្មួយៗនឹងអាចទទួលបានព័ត៌មានកាន់តែច្រើន ដូច្នេះ ការសម្រេចចិត្តរបស់ក្មួយៗក៏នឹងអាចខិតទៅរកភាពត្រឹមត្រូវកាន់តែខ្ពស់។ ទន្ទឹមនេះ បើបានជាសម្រេចចិត្តទៅលើមុខជំនាញណាមួយហើយ ត្រូវបន្តធ្វើវារហូតបានសម្រេច ព្រោះការងាករេ ដូរចុះដូរឡើង ពាក់កណ្តាលទី អាចជាឧបសគ្គក្នុងការឈានទៅសម្រេចគោលដៅ ព្រមទាំងខាតបង់ពេលវេលាថែមទៀតផង។

**ឯកឧត្តម លោកជំទាវ លោក-លោកស្រី លោកគ្រូ-អ្នកគ្រូ និងក្មួយៗទាំងអស់ ជាទីមេត្រី !**

ជាថ្មីម្តងទៀត ខ្ញុំសូមកោតសរសើរ និងវាយតម្លៃខ្ពស់ ចំពោះការខិតខំរៀនសូត្ររបស់ក្មួយៗទាំងអស់ និងសូមអរគុណចំពោះកិច្ចខិតខំប្រឹងប្រែងរបស់ក្រុមការងារមន្ទីរអប់រំ អាជ្ញាធរដែនដី មាតាបិតា-អាណាព្យាបាល លោកគ្រូ-អ្នកគ្រូ និងអ្នកពាក់ព័ន្ធទាំងអស់ ដែលបានរួមចំណែកដល់ការសម្រេចបានជោគជ័យរបស់ក្មួយៗទាំងអស់។ ហើយខ្ញុំក៏សូមបង្ហាញនូវក្តីសង្ឃឹមជឿជាក់យ៉ាងមុតមាំថា ក្មួយៗទាំងអស់នឹងជ្រើសរើសជំនាញសិក្សាបន្តឱ្យបានត្រឹមត្រូវ និងខិតខំប្រឹងប្រែងរៀនសូត្របន្តការសិក្សាថ្នាក់ឧត្តមសិក្សា និងថ្នាក់ក្រោយៗទៀតប្រកបដោយជោគជ័យ ដើម្បីអភិវឌ្ឍចំណេះដឹងរបស់ខ្លួន បង្កើនភាពរឹងមាំនៃសេដ្ឋកិច្ចគ្រួសារ និងចូលរួមចំណែកអភិវឌ្ឍប្រទេសជាតិយើង។

ជាទីបញ្ចប់ ខ្ញុំសូមជូនពរគណៈអធិបតី លោក-លោកស្រី លោកនាយក-នាយករង លោកគ្រូ-អ្នកគ្រូ មាតាបិតា-អាណាព្យាបាល និងក្មួយៗទាំងអស់ សូមបានប្រកបដោយពុទ្ធពរទាំងបួនប្រការ គឺ អាយុ វណ្ណៈ សុខៈ ពលៈ កុំបីឃ្លៀងឃ្លាតឡើយ។

**សូមអរគុណ!!!**